**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ៣០.៣ ក.ប/ប្រ.ក.ក.ល.ក

# ប្រកាស
# ស្តីពី
# ភាពជាតំណាងបំផុតនៃសហជីព និងបែបបទនិងនីតិវិធី ដើម្បីទទួលបានភាពជាតំណាងបំផុត

## រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៦/០០៧ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហជីព
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សម្រេច

**ប្រការ១ .-**

ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌដូចខាងក្រោម៖

- សហគ្រាស គ្រឹះស្ថាន ឬ
- វិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយ។



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៨៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

**ប្រការ២ ._**

ដើម្បីទទួលបានភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន សហជីពត្រូវបំពេញលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

១- បានចុះបញ្ជីត្រឹមត្រូវ។

២- មានកម្មវិធី និងសកម្មភាពដែលបង្ហាញថាសហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួនដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។

៣- មានសមាជិកដែលមានបណ្ណសម្គាល់ និងបញ្ជីឈ្មោះសមាជិកត្រឹមត្រូវច្រើនជាងគេ ឬទទួលបានការបោះឆ្នោតគាំទ្រច្រើនជាងគេនៅក្នុងសហគ្រាស គ្រឹះស្ថានមួយ ដូចករណីខាងក្រោម៖

- សហជីពដែលមានសមាជិកចាប់ពី ៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាស គ្រឹះស្ថានដែលមានសហជីពតែមួយ ឬ

- សហជីពណាដែលស្វែងរកបានការគាំទ្រពីសហជីពដទៃច្រើនជាងគេបំផុត ដោយលើសពី ៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបក្នុងសហគ្រាស គ្រឹះស្ថាន ដែលមានសហជីពលើសពី ១(មួយ) ឬ

- ក្នុងករណីសហជីពណាមួយពុំអាចរកសមាជិកគាំទ្របានចាប់ពី ៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុប ត្រូវរៀបចំការបោះឆ្នោតស្វែងរកការគាំទ្រឲ្យបានសំឡេងច្រើនជាងគេបំផុតលើសពី ៣០%(សាមសិបភាគរយ) នៃចំនួនកម្មករនិយោជិតសរុបនៅក្នុងសហគ្រាស គ្រឹះស្ថាននោះ។ ក្នុងករណីនេះ គ្រប់សហជីពទាំងអស់នៅក្នុងសហគ្រាស គ្រឹះស្ថាន ត្រូវរួមប្រជុំគ្នាដើម្បីកំណត់នីតិវិធីកាលបរិច្ឆេទ ពេលវេលា និងទីកន្លែងបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុត និងត្រូវជូនដំណឹងអំពីព័ត៌មានទាំងនេះដល់កម្មករនិយោជិត និងនិយោជក យ៉ាងហោចណាស់ ១៥(ដប់ប្រាំ)ថ្ងៃ មុនថ្ងៃបោះឆ្នោត។

**ប្រការ៣ ._**

ដើម្បីទទួលបានភាពជាតំណាងបំផុតនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយ សហជីពត្រូវបំពេញលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

១- បានចុះបញ្ជីត្រឹមត្រូវ។

២- មានកម្មវិធី និងសកម្មភាពដែលបង្ហាញថាសហជីពនោះមានលទ្ធភាពផ្តល់សេវាខាងវិជ្ជាជីវៈ វប្បធម៌ និងអប់រំដល់សមាជិករបស់ខ្លួនដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។

៣- មានសមាជិកដែលមានបណ្ណសម្គាល់ត្រឹមត្រូវច្រើនជាងគេនៃចំនួនកម្មករនិយោជិតទាំងអស់ក្នុងវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យនោះ។

**ប្រការ៤ ._**

ការបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុតត្រូវធ្វើទៅតាមនីតិវិធីដូចខាងក្រោម៖

១-កម្មករនិយោជិតពេញសិទ្ធិទាំងអស់នៃសហគ្រាស គ្រឹះស្ថាន មានសិទ្ធិចូលរួមក្នុងការបោះឆ្នោត។

២-សហជីពអាចធ្វើយុទ្ធនាការឃោសនាអំពីព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងការបោះឆ្នោត រួមទាំងកម្មវិធីការងាររបស់ខ្លួននៅពេលទទួលបានភាពជាតំណាងបំផុតដល់កម្មករនិយោជិត ដើម្បីជាមូលដ្ឋានក្នុងការ

បោះឆ្នោត។ ការធ្វើយុទ្ធនាការនេះត្រូវប្រព្រឹត្តទៅនៅក្រៅម៉ោងធ្វើការ ឬក្នុងម៉ោងធ្វើការ នៅក្នុងសហគ្រាស គ្រឹះស្ថាន ប្រសិនបើមានការយល់ព្រមពីនិយោជក និងស្របតាមបែបបទដែលនិយោជកបានយល់ព្រម។

៣-សហជីពអាចកំណត់ឲ្យមានអ្នកសង្កេតការណ៍ដែលអាចជាតំណាងសហព័ន្ធសហជីព សហភាពសហជីព ឬក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យដំណើរការនៃការបោះឆ្នោតនេះ។

៤-ការបោះឆ្នោតត្រូវធ្វើជាសម្ងាត់។

៥-សន្លឹកឆ្នោតត្រូវរាប់ និងប្រកាសលទ្ធផលជាសាធារណៈ បន្ទាប់ពីការបោះឆ្នោតនេះបានបញ្ចប់រួចភ្លាម។

៦-កំណត់ហេតុនៃការបោះឆ្នោតនេះត្រូវចុះហត្ថលេខាពីគ្រប់តំណាងសហជីពដែលបានចូលរួម។

ដើម្បីរៀបចំការបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុតនេះ និយោជកត្រូវបង្កលក្ខណៈងាយស្រួលដល់កម្មករនិយោជិតពេញសិទ្ធិទាំងអស់ ដោយផ្តល់ពេលវេលានៅចុងម៉ោងការងារ ឬពេលវេលាណាមួយ ដែលទទួលបានការឯកភាពរវាងនិយោជកនិងគ្រប់សហជីពមូលដ្ឋានទាំងអស់នៅក្នុងសហគ្រាស គ្រឹះស្ថាននោះ។

រាល់ការធ្វើបណ្តឹងទាក់ទងដល់ដំណើរការនៃការបោះឆ្នោត ឬលទ្ធផលបោះឆ្នោតនេះ ត្រូវដាក់ជូនទៅតុលាការការងារក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីថ្ងៃប្រកាសលទ្ធផល។ ការធ្វើបណ្តឹងនេះមិនមានផលធ្វើឲ្យផ្អាកការអនុវត្តលទ្ធផលនៃការបោះឆ្នោតឡើយ។

**ប្រការ៥ ._**

សហជីពត្រូវដាក់សំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតនៅអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដូចខាងក្រោម៖

១-ចំពោះសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថានដែលមានអាសយដ្ឋាននៅតាមបណ្តាខេត្ត ត្រូវដាក់នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តនោះ ដើម្បីបញ្ជូនមកនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

២-ចំពោះសហជីពមូលដ្ឋាននៃសហគ្រាស គ្រឹះស្ថានដែលមានអាសយដ្ឋាននៅរាជធានីភ្នំពេញ ថ្នាក់សហព័ន្ធសហជីព និងថ្នាក់សហភាពសហជីព ត្រូវដាក់នៅនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**ប្រការ៦ ._**

សំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត មានដូចខាងក្រោម៖

១- ពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត ចំនួន ០១ច្បាប់ដើម។

២- សេចក្តីថតចម្លងលិខិតបញ្ជាក់ការចុះបញ្ជី ឬលិខិតទទួលស្គាល់ថ្នាក់ដឹកនាំសហជីព ចំនួន ០២ច្បាប់ បើមាន។

៣- បញ្ជីឈ្មោះសមាជិកដែលមានបណ្ណសម្គាល់ត្រឹមត្រូវ ចំនួន ០២ច្បាប់។

៤- ក្នុងករណីមានការបោះឆ្នោត ត្រូវមានកំណត់ហេតុនៃការបោះឆ្នោត ដោយភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះសហជីពដែលឈរឈ្មោះ និងបញ្ជីឈ្មោះអ្នកចូលរួមបោះឆ្នោតជ្រើសរើសសហជីពដែលមានភាពជាតំណាងបំផុត ចំនួន០២ច្បាប់។

មានតែអ្នកដឹកនាំគ្រប់គ្រង និងអ្នកទទួលខុសត្រូវកិច្ចការរដ្ឋបាលនៃសហជីពដែលស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតប៉ុណ្ណោះ ទើបមានសិទ្ធិក្នុងការយកសំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតនេះ ដាក់ជូនអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត។

**ប្រការ៧ ._**

ក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការយ៉ាងយូរ ក្រោយពេលបានទទួលសំណុំបែបបទ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ត្រូវសម្រេចជាផ្លូវការអំពីការទទួលស្គាល់ភាពជាតំណាងបំផុតរបស់សហជីពដែលបានបំពេញតាមលក្ខណវិនិច្ឆ័យដូចមានចែងក្នុងប្រកាសនេះ។

**ប្រការ៨ ._**

បន្ទាប់ពីទទួលបានសំណុំបែបបទស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីព អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ត្រូវចេញបង្កាន់ដៃបញ្ជាក់ទទួលសំណុំបែបបទសុំបញ្ជាក់ភាពជាតំណាងបំផុតឲ្យសហជីពនោះវិញ។ បង្កាន់ដៃនេះត្រូវបញ្ជាក់ថាសំណុំបែបបទនោះមានឯកសារដែលតម្រូវឲ្យភ្ជាប់មកជាមួយគ្រប់គ្រាន់ហើយ និងត្រូវកំណត់អំពីកាលបរិច្ឆេទនៃការណាត់ជួបជាមួយអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដើម្បីពិនិត្យសំណុំបែបបទឡើងវិញ។

ក្នុងករណីដែលម្ចាស់សំណុំបែបបទមិនបានមកជួបមន្ត្រីនៃអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត តាមការកំណត់ដោយគ្មានមូលហេតុសមរម្យ នោះពាក្យស្នើសុំនឹងមិនត្រូវបានធ្វើចំណាត់ការបន្ត។

ក្នុងករណីដែលសំណុំបែបបទនោះមានភាពមិនសមស្របត្រង់ចំណុចណាមួយ អ្នកស្នើសុំត្រូវទទួលយកសំណុំបែបបទនោះទៅធ្វើការកែសម្រួល ឬបំពេញបន្ថែមឲ្យបានត្រឹមត្រូវ រួចយកទៅដាក់ជូនជាថ្មីទៀតនៅអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតតាមការកំណត់របស់មន្ត្រីនៃអង្គភាពនោះ។ រយៈពេលទទួលយកសំណុំបែបបទទៅកែសម្រួល ឬបំពេញបន្ថែមនោះ មិនគិតចូលក្នុងចិរវេលាដែលកំណត់ដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះទេ។

ក្នុងករណីដែលអ្នកស្នើសុំមិនបានកែសម្រួល ឬបំពេញបន្ថែមនូវចំណុចដែលមិនសមស្របទៅតាមការកំណត់របស់មន្ត្រីនៃអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដោយគ្មានមូលហេតុសមរម្យ នោះពាក្យស្នើសុំនឹងមិនត្រូវបានធ្វើចំណាត់ការបន្ត។

**ប្រការ៩._**

សហជីពសាមីអាចធ្វើឧបាស្រ័យទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីមិនទទួលបានចំណាត់ការរបស់អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដូចមានចែងក្នុងប្រការ៧ និងប្រការ៨ នៃប្រកាសនេះ។

រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនឹងផ្តល់ការសម្រេចលើពាក្យសុំធ្វើឧបាស្រ័យក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃនៃថ្ងៃធ្វើការ ក្រោយការទទួលបានពាក្យស្នើសុំធ្វើឧបាស្រ័យនេះ។

**ប្រការ១០ ._**

បន្ទាប់ពីទទួលបានពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត ដែលមានលក្ខណៈពេញលេញនិងត្រឹមត្រូវហើយនោះ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតត្រូវជូនដំណឹងអំពីការដាក់ពាក្យស្នើសុំ

នេះតាមរយៈសំបុត្រអនុសិដ្ឋ ឬសំបុត្រជូនផ្ទាល់ដៃដែលមានចុះហត្ថលេខាថាបានទទួល ទៅដល់អ្នកគ្រប់គ្រងសហគ្រាស គ្រឹះស្ថានឬនិយោជក និងសហជីពដទៃនៅក្នុងសហគ្រាស គ្រឹះស្ថាន ចំពោះភាពជាតំណាងបំផុតនៅថ្នាក់សហគ្រាស គ្រឹះស្ថាន។

ចំពោះភាពជាតំណាងបំផុតនៅក្នុងវិជ្ជាជីវៈមួយ ឬសកម្មភាពសេដ្ឋកិច្ចមួយ ឬវិស័យមួយ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ត្រូវជូនដំណឹងអំពីការដាក់ពាក្យស្នើសុំដល់អ្នកគ្រប់គ្រងសហគ្រាស គ្រឹះស្ថានឬនិយោជក សមាគមនិយោជក សហព័ន្ធសហជីព និងសហភាពសហជីពដែលពាក់ព័ន្ធនឹងវិជ្ជាជីវៈនោះ ឬសកម្មភាពសេដ្ឋកិច្ចនោះ ឬវិស័យនោះ តាមរយៈសំបុត្រអនុសិដ្ឋ ឬសំបុត្រជូនផ្ទាល់ដៃដែលមានចុះហត្ថលេខាថាបានទទួល។

បន្ទាប់ពីបានទទួលការជូនដំណឹងខាងលើ ក្នុងរយៈពេល ១០(ដប់)ថ្ងៃនៃថ្ងៃធ្វើការ និយោជកត្រូវបិទប្រកាសពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត នៅទីណាមួយដ៏សមរម្យ អាចចូលទៅមើលបានដោយងាយក្នុងកន្លែងធ្វើការ។ ក្នុងរយៈពេលនេះ បុគ្គលពាក់ព័ន្ធអាចផ្តល់នូវសេចក្តីសង្កេត ឬសេចក្តីជំទាស់ជាយថាហេតុរបស់ខ្លួន ទៅនឹងពាក្យស្នើសុំនេះបាន។

ផុតរយៈពេលនេះ ប្រសិនបើគ្មានការជំទាស់ណាមួយទេ ទើបអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត អាចចេញសេចក្តីបញ្ជាក់ភាពជាតំណាងបំផុតបាន។

**ប្រការ១១ ._**

រាល់បណ្តឹងជំទាស់នឹងពាក្យស្នើសុំភាពជាតំណាងបំផុតត្រូវប្តឹងទៅអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតដែលបានទទួលសំណុំបែបបទស្នើសុំបញ្ជាក់នោះ ក្នុងរយៈពេលកំណត់ដូចមានចែងក្នុងប្រការ១០ នៃប្រកាសនេះ។

សហភាពសហជីព ឬសហព័ន្ធសហជីព ដែលមិនមានសហជីពមូលដ្ឋានក្នុងសហគ្រាស គ្រឹះស្ថាន ឬសហជីពមូលដ្ឋានដែលមិនទាន់ចុះបញ្ជី មិនអាចធ្វើការជំទាស់ទៅលើការដាក់ពាក្យស្នើសុំបញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពសាមីឡើយ។

រាល់ការជំទាស់ត្រូវតែមានភស្តុតាងដូចជាសក្ខីភាពដែលផ្តល់ឲ្យដោយកម្មករនិយោជិត (ចុះហត្ថលេខា ឬផ្តិតម្រាមដៃ) ឬឯកសារផ្សេងទៀត និងដោយផ្អែកលើមូលហេតុដូចខាងក្រោម៖

១- សហជីពដាក់ពាក្យស្នើសុំនោះ ពុំទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការស្នើសុំបញ្ជាក់ភាពជាតំណាងបំផុត។

២- សហជីពដាក់ពាក្យស្នើសុំនោះ បានក្លែងបន្លំពាក្យស្នើសុំរបស់ខ្លួន។

៣- មូលហេតុសមរម្យផ្សេងទៀត។

នៅមុនពេលទទួលយកការជំទាស់ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត នឹងជួបជាមួយភាគីពាក់ព័ន្ធដើម្បីត្រួតពិនិត្យ និងធ្វើការផ្ទៀងផ្ទាត់ភស្តុតាងទាំងឡាយដែលបានផ្តល់ឲ្យ។ សហជីពដែលត្រូវបានគេជំទាស់ ត្រូវផ្តល់ឲ្យអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតនូវរាល់ភស្តុតាងដែលប្រើជាមូលដ្ឋានក្នុងការការពារនៃការជំទាស់នោះ។

ប្រសិនបើការជំទាស់ត្រូវបានទទួលយក អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត នឹងជូនដំណឹងទៅនិយោជក និងសហជីពពាក់ព័ន្ធតាមសំបុត្រអនុសិដ្ឋ ឬសំបុត្រជូនផ្ទាល់ដៃដែលមានចុះហត្ថលេខា

ថាបានទទួល ដោយមានការពន្យល់ពីហេតុផលនៃការទទួលយកការជំទាស់នោះ។ ប្រសិនបើអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតបដិសេធការស្នើជំទាស់ណាមួយនោះ អង្គភាពនឹងចេញសេចក្ដីបញ្ជាក់ដល់សហជីពដែលដាក់ពាក្យសុំជំទាស់នោះ ព្រមទាំងមានការពន្យល់ពីហេតុផលផងដែរ។

អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតមានសិទ្ធិស្នើសុំនូវព័ត៌មានបន្ថែមពីនិយោជក ដូចជាចំនួនកម្មករនិយោជិតសរុបដែលកំពុងធ្វើការនាពេលបច្ចុប្បន្ននៅក្នុងសហគ្រាស គ្រឹះស្ថាន ឬផ្នែកណាមួយនៃសហគ្រាស គ្រឹះស្ថាន ច្បាប់ចម្លងនៃឯកសារដែលជាប់ទាក់ទងនឹងកាត់ភាគទានសហជីពដូចដែលបានស្នើឡើងដោយសហជីព ឬក៏ព័ត៌មានពាក់ព័ន្ធទាំងឡាយផ្សេងៗ ទៀតដែលចាំបាច់។

**ប្រការ១២ .-**

និយោជកត្រូវរក្សាទុក និងធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះកម្មករនិយោជិតប្រចាំខែ ដែលមានបញ្ជាក់ឈ្មោះ ប្រភេទកិច្ចសន្យាការងារ និងប្រភេទការងារ សម្រាប់ការត្រួតពិនិត្យភ្លាមៗ ក្នុងករណីដែលសហជីពសុំបញ្ជាក់ភាពជាតំណាងបំផុត។

**ប្រការ១៣ .-**

សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្ដាច់មុខក្នុងការដោះស្រាយវិវាទការងាររួម ដែលកើតចេញពីខចែងទាំងឡាយក្នុងអនុសញ្ញារួម។

សហជីពដែលមានភាពជាតំណាងបំផុតមានករណីយកិច្ចដូចខាងក្រោម៖

- ចរចាដោយស្មោះត្រង់ជាមួយនិយោជកក្នុងគោលបំណងឲ្យមានការព្រមព្រៀងជាសមូហភាពទៅលើអនុសញ្ញារួមដែលផ្ដោតទៅលើលក្ខខណ្ឌការងារ អនាម័យសន្តិសុខការងារ និងអត្ថប្រយោជន៍ផ្សេងៗ ទៀត
- ធ្វើជាតំណាងដោយស្មោះត្រង់ឲ្យកម្មករនិយោជិត ដែលមិនមែនជាសមាជិករបស់ខ្លួននៅក្នុងបណ្ដឹងតវ៉ាមិនសុខចិត្តដែលកើតចេញពីអនុសញ្ញារួម
- ធ្វើជាតំណាងដោយស្មោះត្រង់ឲ្យកម្មករនិយោជិតចំពោះវិវាទផ្សេងៗទៀត ដែលមិនកើតចេញពីអនុសញ្ញារួម តាមសំណើរបស់កម្មករនិយោជិត ឬសហជីពដែលមានសមាជិកភាគតិចនៅក្នុងសហគ្រាស គ្រឹះស្ថាន
- មិនត្រូវរើសអើងនៅក្នុងពេលទទួលយកសមាជិកថ្មី
- បែងចែកអាសនៈនៅក្នុងយន្តការមួយចំនួនដែលបានកំណត់ក្នុងច្បាប់ស្ដីពីការងារ។

**ប្រការ១៤ .-**

សហជីពដែលមានសមាជិកភាគតិចទាំងឡាយនៅក្នុងសហគ្រាស គ្រឹះស្ថានដែលមានសហជីពមានភាពជាតំណាងបំផុតត្រូវបានបញ្ជាក់រួច ហើយដែលកំពុងស្ថិតនៅក្នុងសុពលភាពត្រូវបានហាមឃាត់លើការទាមទារសិទ្ធិចរចាអនុសញ្ញារួម និងការទាមទារសិទ្ធិ ឬអត្ថប្រយោជន៍ផ្សេងៗដែលលើសពីអត្ថប្រយោជន៍ចែងនៅក្នុងច្បាប់ បទបញ្ញា អនុសញ្ញារួមដែលកំពុងមានសុពលភាព ឬវិធានការងារផ្ទៃក្នុងទាំងឡាយ។ សិទ្ធិ និងតួនាទីរបស់សហជីពដែលមានសមាជិកភាគតិចរួមមាន៖

- ធ្វើជាតំណាងដោយស្មោះត្រង់ឲ្យសមាជិករបស់ខ្លួនក្នុងការដោះស្រាយវិវាទការងាររួមដែលមិនកើតចេញពីអនុសញ្ញារួម
- ការធ្វើជាតំណាងសមាជិករបស់ខ្លួននៅក្នុងការដោះស្រាយវិវាទបុគ្គល
- ការផ្តល់វគ្គបណ្តុះបណ្តាលស្តីពីចំណេះដឹងផ្នែកច្បាប់ និងវិជ្ជាជីវៈ
- ការផ្តល់ប្រឹក្សាផ្នែកច្បាប់ និងការអនុវត្តជាក់ស្តែងដល់សមាជិករបស់ខ្លួន
- ការចូលរួមនៅក្នុងយន្តការកិច្ចសហការនៅកន្លែងការងារដែលប្រព្រឹត្តទៅជាប្រចាំ
- ការចូលរួមប្រឹក្សាយោបល់នៅក្នុងយន្តការទីផ្សារការងារ
- ការផ្តល់ព័ត៌មានពាក់ព័ន្ធនឹងសមាជិករបស់ខ្លួន
- ការរៀបចំបង្កើតនូវសហករណ៍ដែលអាចជាហាងលក់ដូរឥវ៉ាន់ អាហារដ្ឋាន ឬការថែរក្សាសុខភាព ។ល។ សម្រាប់សម្រួលដល់ជីវភាពរស់នៅរបស់សមាជិកខ្លួន
- តួនាទីផ្នែករដ្ឋបាលនៅក្នុងការផ្តល់ឲ្យនូវអត្ថប្រយោជន៍ដល់សមាជិករបស់ខ្លួនពេលគ្មានការងារធ្វើ។

សហជីពមានភាពជាតំណាងបំផុតក៏អាចអនុវត្តតួនាទីដែលមានកំណត់ក្នុងចំណុចខាងលើផងដែរ។

**ប្រការ១៥ .-**

សេចក្តីបញ្ជាក់ភាពជាតំណាងបំផុតរបស់សហជីពមិនអាចត្រូវប្តឹងតវ៉ាបានឡើយ ក្នុងរយៈពេល ២(ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃទទួលបានភាពជាតំណាងបំផុត វៀរលែងតែក្នុងករណីខាងក្រោមនេះ ដែលសហជីពមានភាពជាតំណាងបំផុតអាចបាត់បង់ភាពជាតំណាងបំផុតដោយមិនកំណត់ពេលវេលាៈ

១- នៅពេលដែលត្រូវបានរកឃើញថា សហជីពនោះបានខកខានបំពេញនូវករណីយកិច្ចជាទៀងទាត់របស់ខ្លួនដូចមានចែងក្នុងប្រការ១៣ នៃប្រកាសនេះ ដោយផ្អែកលើភស្តុតាងជាក់ស្តែង រួមទាំងការបដិសេធក្នុងការធ្វើជាតំណាងកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងអនុសញ្ញារួម។

២- នៅពេលដែលបញ្ជិការបស់សហជីពត្រូវបានលុប។

៣- នៅពេលដែលសហជីពត្រូវបានរំលាយ។

៤- នៅពេលណាដែលមានភស្តុតាងបញ្ជាក់ច្បាស់លាស់ថាសហជីពនោះលែងមានភាពជាតំណាងបំផុតទៀតហើយ។

នៅពេលដែលភាពជាតំណាងបំផុតហួសរយៈពេល ២(ពីរ)ឆ្នាំ សហជីពណាមួយដែលមានវត្តមាននៅក្នុងសហគ្រាស គ្រឹះស្ថានតែមួយជាមួយគ្នា ឬនៅក្នុងវិជ្ជាជីវៈ ឬសកម្មភាពសេដ្ឋកិច្ច ឬវិស័យជាមួយគ្នា អាចប្តឹងតវ៉ាទៅនឹងភាពជាតំណាងបំផុតនេះតាមរយៈការស្វែងរកឲ្យមានការទទួលស្គាល់ដូចលក្ខណវិនិច្ឆ័យក្នុងប្រកាសនេះ។

រាល់បណ្តឹងតវ៉ាទៅនឹងភាពជាតំណាងបំផុត ត្រូវធ្វើទៅប្រធានអង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត ដែលបានទទួលសំណុំបែបបទនោះ។ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុតអាចចាត់ឲ្យមានការអង្កេត ប្រសិនបើចាំបាច់ត្រូវពិនិត្យឡើងវិញភាពជាតំណាងបំផុតរបស់សហជីពណាមួយ។ អង្គភាពទទួលបន្ទុកបញ្ជាក់ភាពជាតំណាងបំផុត អាចព្យួរ ឬដកហូតភាពជាតំណាងបំផុតរបស់សហជីពក្នុងករណីមានភស្តុតាងជាក់ច្បាស់ថាមានការរំលោភបំពាន ឬបាត់បង់លក្ខណវិនិច្ឆ័យដូចមានចែងក្នុងច្បាប់ស្តីពីសហជីព។

**ប្រការ១៦ ._**

ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួមត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។

**ប្រការ១៧ ._**

ប្រកាសលេខ៣០៥ សកបយ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០០១ ស្តីពីភាពជាតំណាងរបស់អង្គការវិជ្ជាជីវៈនៃកម្មករនិយោជិត នៅថ្នាក់សហគ្រាស គ្រឹះស្ថាន និងសិទ្ធិក្នុងការចរចាជាសមូហភាពដើម្បីចុះអនុសញ្ញារួមនៅថ្នាក់សហគ្រាស គ្រឹះស្ថាន របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៨ ._**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ ប្រធាននាយកដ្ឋានវិវាទការងារ ប្រធានអង្គភាពក្រោមឱវាទនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត ត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗ ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៥កើត ខែ បឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- សាលារាជធានី ខេត្ត
- សហជីព និងសមាគមនិយោជកគ្រប់លំដាប់ថ្នាក់

  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ១៨

  *"ដើម្បីអនុវត្ត"*
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ